**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ០៦០ សសរ.កសក

# សេចក្តីសម្រេចរួម

## ស្តីពី

## ការកំណត់ថ្លៃឈ្នួលឡូត៍នេសាទសម្រាប់ធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងកែលំអ ក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និងខេត្តបន្ទាយមានជ័យ សម្រាប់វេននេសាទឆ្នាំ ២០០៦-២០០៧ និង ២០០៧-២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៨៩ ស្តីពី ការជួលដែននេសាទទឹកសាប និងសមុទ្រឱ្យធ្វើអាជីវកម្ម
- បានឃើញប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ១៩៨៩ ស្តីពី ការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទបំរុងទុកនៅទឹកសាប
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០៣ លេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០៥ មីនា ឆ្នាំ ២០០១ លេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០១ និងលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០១ លេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០១ លេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០១ លេខ ៣០ អនក្រ.បក

ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០០១ លេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០១ ស្តីពីការលុប និង កាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទខេត្តកណ្តាល ព្រៃវែង តាកែវ កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និង ខេត្តបន្ទាយមានជ័យទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

- បានឃើញបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ៣០ បប. ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសេចក្តីសម្រេចលេខ ០០៨ សសរ.កសក ចុះថ្ងៃទី ១៣/០១/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ជា ប៉េងអ៊ាន និង លោក កាំង លី កាន់កាប់ធ្វើអាជីវកម្មនេសាទឡូត៍បឹងព្រែកលេខ ០៤ ខេត្តកណ្តាល រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៣១៣ សសរ.កសក ចុះថ្ងៃទី ០៤/១០/២០០៤ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ប៊ុត ចាន់ធូ កាន់កាប់ធ្វើអាជីវកម្មនេសាទឡូត៍បឹងព្រែកលេខ ១៨ ខេត្តកណ្តាល រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ២០៨ សសរ.កសក ចុះថ្ងៃទី ១០/០៧/២០០៦ ស្តីពី ប្រគល់សិទ្ធិឱ្យលោកស្រី ប៊ុត វណ្ណារី កាន់កាប់ធ្វើអាជីវកម្មនេសាទឡូត៍ដាយត្រីលេខ ១៥ដេ ខេត្តកណ្តាល រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៤០៩ សសរ.កសក ចុះថ្ងៃទី ១៩/០៨/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ប៊ុត ឡែអាត់ កាន់កាប់ធ្វើអាជីវកម្មនេសាទឡូត៍បឹងព្រែកលេខ ០៣ ខេត្តព្រៃវែង រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៤០៩ សសរ.កសក ចុះថ្ងៃទី ១៩/០៨/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ជា ឈាត កាន់កាប់ធ្វើអាជីវកម្មនេសាទឡូត៍បឹងព្រែកលេខ ០៤ ខេត្តព្រៃវែង រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញចំណារឯកភាពលេខ ៣៩៣៥ កសក. ចុះថ្ងៃទី ០៧/០៧/២០០៦ ស្តីពី ការអនុញ្ញាតឱ្យលោក សេង សារឿន ធ្វើការអភិវឌ្ឍន៍ឡូត៍នេសាទលេខ ១៨ ខេត្តព្រៃវែង ឡើងវិញសម្រាប់រយៈពេល ២ ឆ្នាំ ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៨ ជាការសាកល្បង
- បានឃើញចំណារឯកភាពលេខ ៣៨៣៦ កសក. ចុះថ្ងៃទី ១៩/០៧/២០០៦ ស្តីពី ការអនុញ្ញាតឱ្យលោកស្រី ជ្រូក ចាន់ថន ធ្វើអាជីវកម្មដាយបង្កងលេខ ១អា ខេត្តព្រៃវែងសម្រាប់រយៈពេល ១ឆ្នាំ ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧ ជាការសាកល្បង
- បានឃើញសេចក្តីសម្រេចលេខ ១១២ សសរ.កសក ចុះថ្ងៃទី ០៧/០៣/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោកស្រី ស៊ុយ វណ្ណា កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០១ ខេត្តកំពង់ចាម រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៣០០ សសរ.កសក ចុះថ្ងៃទី ៣០/០៦/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ស៊ុន គុប កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០៣ ខេត្តកំពង់ធំ រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៣០១ សសរ.កសក ចុះថ្ងៃទី ៣០/០៦/២០០៥ ស្តីពីប្រគល់សិទ្ធិឱ្យលោក ស៊ាង គ្រេង កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០៧ ខេត្តកំពង់ធំ រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ ២៨១ សសរ.កសក ចុះថ្ងៃទី ១៣/០៦/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក សុខ ម៉ៅ កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០៤ ខេត្តកំពង់ឆ្នាំង រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញសេចក្តីសម្រេចលេខ ២៨២ សសរ.កសក ចុះថ្ងៃទី ១៣/០៦/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ស្រេង សុខាក់ កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០៨ ខេត្តកំពង់ឆ្នាំង រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ២៨៣ សសរ.កសក ចុះថ្ងៃទី ១៣/០៦/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ស៊្រុន រស់ កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ១១ ខេត្តកំពង់ឆ្នាំង រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ១១៤ សសរ.កសក ចុះថ្ងៃទី ១៦/០៣/២០០៦ ស្តីពី ប្រគល់សិទ្ធិឱ្យលោក ប៊ុត ចាន់ធូ ធ្វើអាជីវកម្មអភិវឌ្ឍន៍កែលំអឡូត៍នេសាទលេខ ០៥ ខេត្តតាកែវ រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញសេចក្តីសម្រេចលេខ ៤០២ សសរ.កសក ចុះថ្ងៃទី ១១/០៨/២០០៥ ស្តីពី ប្រគល់សិទ្ធិឱ្យលោក គោត ម៉ាត់ កាន់កាប់ឡូត៍នេសាទឡូត៍បឹងព្រែកលេខ ០២ ខេត្តបន្ទាយមានជ័យ រយៈពេលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញកំណត់ហេតុប្រជុំថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០០៦ ស្តីពី ការកំណត់ថ្លៃឈ្នួលឡូត៍នេសាទក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និង ខេត្តបន្ទាយមានជ័យសម្រាប់រដូវនេសាទពីឆ្នាំ ២០០៦-២០០៧ និង ២០០៧-២០០៨

## **ស ម្រេ ច**

**ប្រការ ១ :** កំណត់ថ្លៃឈ្នួលឡូត៍នេសាទដែលសម្រាប់ធ្វើអាជីវកម្មនេសាទ ការអភិវឌ្ឍន៍ និងកែលំអដែននេសាទ សម្រាប់អាណត្តិនេសាទឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៨ ដែលមាននៅក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និង ខេត្តបន្ទាយមានជ័យ ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនេះ ។

**ប្រការ ២ :** សេចក្តីសម្រេចណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី** **រដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**គាត ឈន់** **ចាន់ សារុន**

**<u>ចម្លងជូន</u> :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងជំនាញ
- សាលាខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និង បន្ទាយមានជ័យ "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

ភ្ជាប់សេចក្តីសម្រេចលេខ សសរ.កសក. ចុះថ្ងៃទី ខែ ឆ្នាំ ២០០៦ ស្តីពី ការកំណត់ថ្លៃឈ្នួលឡូត៍នេសាទ សម្រាប់ធ្វើអាជីវកម្មអភិវឌ្ឍន៍ និង កែលំអក្នុងខេត្តកណ្តាល ព្រៃវែង កំពង់ចាម កំពង់ធំ កំពង់ឆ្នាំង តាកែវ និង បន្ទាយមានជ័យសម្រាប់រដូវនេសាទឆ្នាំ ២០០៦-២០០៧ និង ២០០៧-២០០៨។

| ល.រ | ខេត្ត | ប្រភេទ ឡូត៍នេសាទ | អ្នកទទួលសិទ្ធិកាន់កាប់ | ថ្លៃឈ្នួលកំណត់ក្នុងមួយរដូវនេសាទ | ផ្សេងៗ |
|---|---|---|---|---|---|
| | កណ្តាល | ឡូត៍បឹងព្រែក | | | |
| ១ | | 04 | ជា ប៉េងអ៊ាន/កាំងលី | 60.000.000៛ | |
| ២ | | 18 | ប៊ុត ចាន់ធូ | 67.000.000៛ | |
| | | ឡូត៍ដាយត្រី | អ្នកស្រី ប៊ុត វណ្ណារី | | |
| ៣ | | 15D | | 17.000.000៛ | |
| សរុប ក : | | | | 144.000.000៛ | |
| | ព្រៃវែង | ឡូត៍បឹងព្រែក | | | |
| ៤ | | 03 | ប៊ុត ឡៃអាត់ | 20.000.000៛ | |
| ៥ | | 04 | ជា ឈាត | 53.000.000៛ | |
| ៦ | | 18 | សេង សារឿន | 42.000.000៛ | |
| | | ឡូត៍ដាយបង្កង | | | |
| ៧ | | 1A | អ្នកស្រីជ្រូក ចាន់ថន | 6.000.000៛ | |
| សរុប ខ : | | | | 121.000.000៛ | |
| | កំពង់ចាម | ឡូត៍បឹងព្រែក | | | |
| ៨ | | 01 | អ្នកស្រី ស៊ុយ វណ្ណា | 44.700.000៛ | |
| សរុប គ : | | | | 44.700.000៛ | |
| | កំពង់ធំ | ឡូត៍បឹងព្រែក | | | |
| ៩ | | 03 | ស៊ុន តុប | 137.000.000៛ | |
| ១០ | | 07 | ស៊ាង ក្រេង | 66.000.000៛ | |
| សរុប ឃ : | | | | 203.000.000៛ | |

| ល.រ | ខេត្ត | ប្រភេទ ឡូត៍នេសាទ | អ្នកទទួលសិទ្ធិ កាន់កាប់ | ថ្លៃឈ្នួលកំណត់ក្នុងមួយ រដូវនេសាទ | ផ្សេងៗ |
|---|---|---|---|---|---|
| | កំពង់ឆ្នាំង | ឡូត៍បឹងព្រែក | | | |
| ១១ | | 04 | សុខ ម៉ៅ | 47.000.000៛ | |
| ១២ | | 08 | ស្រេង សុខាត់ | 64.000.000៛ | |
| ១៣ | | 11 | ស្រ៊ុន រស់ | 49.000.000៛ | |
| សរុប ង : | | | | 160.000.000៛ | |
| | តាកែវ | ឡូត៍បឹងព្រែក | | | |
| ១៤ | | 05 | ប៊ុត ចាន់ធូ | 42.000.000៛ | |
| សរុប ច : | | | | 42.000.000៛ | |
| | បន្ទាយ | ឡូត៍បឹងព្រែក | | | |
| ១៥ | មានជ័យ | 02 | រោគ ម៉ាត់ | 43.000.000៛ | |
| សរុប ឆ : | | | | 43.000.000៛ | |
| សរុបរួម "ក ខ គ ឃ ង ច ឆ" : | | | | 757.700.000៛ | |

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់ សារុន